# ការយល់ឃើញរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិលកម្ពុជាអំពីសេរីភាពមូលដ្ឋាន៖ ការវិវឌ្ឍន៍រយៈពេល៥ ឆ្នាំ

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានគឺជាគម្រោងរយៈពេលវែងដែលឃ្លាំមើលលំហសង្គមស៊ីវិលនៅប្រទេសកម្ពុជា និងជាពិសេសទៅលើលទ្ធភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ("សេរីភាពមូលដ្ឋាន")។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានគឺជាគំនិតផ្តួចផ្តើមរួមគ្នារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(អាដហុក) មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ។

គោលដៅសំខាន់នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺចង់ស្វែងយល់ថាតើថ្នាក់ដឹកនាំសង្គមស៊ីវិល ថ្នាក់ដឹកនាំសហជីព និងថ្នាក់ដឹកនាំសហព័ន្ធសហជីព (ថ្នាក់ដឹកនាំសហជីព) យល់ឃើញអំពីលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តសេរីភាពមូលដ្ឋានបានកម្រិតណា។ ដើម្បីប្រមូលយកព័ត៌មាននេះ ការស្ទង់មតិរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងថ្នាក់ដឹកនាំសហជីព ត្រូវបានធ្វើឡើងក្នុងកំឡុងពេលនៃការធ្វើរបាយការណ៍ប្រចាំឆ្នាំនីមួយៗនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។[1]

**មានថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលច្រើនជាងថ្នាក់ដឹកនាំ សហជីព**ឆ្លើយតបការស្ទង់មតិនេះជារៀងរាល់ឆ្នាំ។




**<u>ការវិវឌ្ឍន៍សំខាន់ៗសម្រាប់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព</u>**

រាជរដ្ឋាភិបាលកម្ពុជាធ្វើការ**តាមដានសកម្មភាពរបស់អង្គការសង្គមស៊ីវិល/សហជីពពីមួយឆ្នាំ ទៅមួយឆ្នាំ**ដោយមានការធ្លាក់ចុះបន្តិចក្នុងឆ្នាំទី៥នេះ។




ភាគច្រើននៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍ថា**ការឃ្លាំមើលពីសំណាក់រដ្ឋាភិបាលគឺទង្វើហួសហេតុ**។




នៅឆ្នាំទី៥នេះ ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពតិចជាងឆ្នាំមុនៗបានរាយការណ៍ថា**ការបង្កើតបណ្តាញ សម្ព័ន្ធសហព័ន្ធ និងសហជីពត្រូវបានរឹតត្បិត**។




[1] ឆ្នាំទី១ចាប់ពីខែមេសា ឆ្នាំ២០១៦ ដល់ខែមីនា ឆ្នាំ២០១៧។ ឆ្នាំទី២ ចាប់ពីខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ ។ ឆ្នាំទី៣ ចាប់ពីខែមេសា ឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០១៩ ។ ឆ្នាំទី៤ ចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០ ។ ឆ្នាំទី៥ ចាប់ពីខែមេសា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២០។

ភាគច្រើននៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព យល់ថា**តម្រូវការរបាយការណ៍មិនមែនហិរញ្ញវត្ថុពីរដ្ឋាភិបាលគឺហួសហេតុ ឬជាបន្ទុកធ្ងន់ធ្ងរ។**




ភាគច្រើននៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព យល់ ថា**មានសេរីភាពខ្លះដែរក្នុងការបញ្ចេញមតិ។**




ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព **រឹតត្បិតខ្លួនឯង**នៅតែមានភាគរយខ្ពស់។




ភាគរយនៃថ្នាក់ដឹកនាំសង្គមស៊ីវិល/សហជីព យល់ថា **មិនមានសុវត្ថិភាពក្នុងការចែករំលែកព័ត៌មានតាមរយៈបណ្តាញសង្គម**នៅតែមានកម្រិតខ្ពស់ជារៀងរាល់ឆ្នាំ។




ភាគរយខ្ពស់នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពយល់ថាអង្គការរបស់ពួកគេត្រូវបាន**ទទួលស្គាល់ថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់**ដោយរដ្ឋាភិបាល។




នៅឆ្នាំទី៥**អង្គការសង្គមស៊ីវិល/សហជីពតិចតួចប៉ុណ្ណោះបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរតាក់តែងច្បាប់**ជាមួយរដ្ឋាភិបាលជាងឆ្នាំមុនៗ ។



## ភាពខុសគ្នារវាងសង្គមស៊ីវិល និងសហជីព

ថ្នាក់ដឹកនាំសហជីពច្រើនជាងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលរាយការណ៍ថាពួកគេប្រឈមនឹងការ**រឹតត្បិតនៅពេលបង្កើត បណ្ដាញ សម្ព័ន្ធ សហព័ន្ធ ឬសហជីពប្រភេទផ្សេងទៀត**។




នៅឆ្នាំទី៥ **ថ្នាក់ដឹកនាំសហជីព** បានរាយការណ៍ថាការ**ឃ្លាំមើលពីសំណាក់រដ្ឋាភិបាលគឺហួសហេតុ** និងជ្រៀតជ្រែកមាន**ភាគរយខ្ពស់ជាង**ជាមួយសកម្មភាពនានារបស់សហជីពមានភាគរយខ្ពស់ជាង បើប្រៀបធៀបទៅនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។




ភាគរយនៃថ្នាក់ដឹកនាំសហជីពដែលយល់ឃើញថាមាន**សេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំបានធ្លាក់ចុះយ៉ាងខ្លាំង**នៅឆ្នាំទី៥ ខណៈដែលភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលសឹងតែមិនមានការប្រែប្រួលក្នុងឆ្នាំកន្លងមក។




ខែសីហា ឆ្នាំ២០២១